# បុព្វភាគប្បដិបត្តិ

បុរសស្រ្តីដែលមានសទ្ធាជ្រះថ្លាក្នុងគុណព្រះរតនត្រៃ គឺគុណព្រះពុទ្ធ ព្រះធម៌ ព្រះ សង្ឃ ហើយប្រាថ្នាប្តេជ្ញាខ្លួនជាអុបាសក រឺជាអុបាសិកា ជាបុព្វភាគប្បដិបត្តិគឺសេចក្តី ប្រតិបត្តិជាចំណែកខាងដើម អោយបានពេញសិប់ជាអ្នកកាន់ព្រះពុទ្ធសាសនា រឺជាអ្នកតម្កល់នៅក្នុងព្រះពុទ្ធសាសនានោះ ដំបូងបង្អស់ត្រូវបញ្ចេញវចីភេទសូមខមាទោសនិងព្រះរតនត្រៃក្នុងទីចំពោះព្រះភក្រ្តព្រះពុទ្ធរូបក៏បាន ចំពោះនិងព្រះសថូប រឺចេតីយ៍ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធក៏បាន ចំពោះមុខបុគ្គល គឺភិក្ខុទាំងឡាយតាំងពី៤ រូបឡើងទៅក៏បាន លុះសូមខមាទោសរួចហើយត្រូវបញ្ចេញវចីភេទពោលប្រកាសប្តេជ្ញាខ្លួនអោយជាអ្នកបានដល់ព្រះត្រៃសរណគមន៍ ជាអុបាសក រឺអុបាសិកាក្នុងព្រះពុទ្ធសាសនាជាខាងក្រោយ រួចហើយត្រូវសមាទាននិច្ចសីលរក្សាអោយខ្ជាប់តទៅ បើមានសទ្ធាជ្រះថ្លា ក៏គប្បីរក្សាអុបោសថសីលតាម កាលកំណត់ដែលត្រូវរក្សាម្តងៗនោះផង និងមានផលានិសង្សច្រើនដោយលំដាប់ៗឡើង។ អែពាក្យសូមខមាទោសនិងព្រះរតនត្រៃនោះ បើបុរសតែម្នាក់ រឺស្រ្តីតែម្នាក់ត្រូវសូត្រថា

អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមុឡ្ហំ យថាអកុសលំ (យោ/យា)ហំភន្តេ កាយេនវា វាចាយ វាមនសា វា (ភគវតោ/ពុទ្ធស្ស) វា ធម្មស្ស វា សង្ឃស្ស វា អគារវំ អកាសឹ (តស្ស/តស្សា)មេ ភន្តេ (ភគវា/ អយ្យោ/ អយ្យា/ សង្ឃោ)អច្ចយំ អច្ចយតោ បដិគ្គណ្ហា(តុ/ តុ/ ន្តុ/ តុ)អាយតឹ សំវរាយ

ប្រែថា : បពិតព្រះ ដ៏មានព្រះភាគ (/ ករុណា / ករុណាទាំងឡាយ / សង្ឃ) ដ៏ចំរើន ទោសកំហុសដែលប្រព្រឹត្តកន្លងគ្របសង្កត់ហើយនូវខ្ញុំព្រះករុណា តាមដោយព្រះករុណាជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស បពិតព្រះ ដ៏មានព្រះភាគ (/ ករុណា / ករុណាទាំងឡាយ / សង្ឃ) ដ៏ចំរើន ក្រែងខ្ញុំព្រះបាធ្វើហើយនូវសេចក្តីល្មើសមិនគោរពដល់ព្រះ ដ៏មានព្រះភាគ(/ ព្រះពុទ្ធជាម្ចាស់) ក្តី ដល់ព្រះធម៌ក្តី ដល់ព្រះសង្ឃក្តី ដោយកាយក្តី ដោយវាចាក្តី ដោយចិត្តក្តី បពិតព្រះដ៏មានព្រះភាគ (/ ករុណា / ករុណាទាំងឡាយ / សង្ឃ) ដ៏ចំរើន សូមព្រះដ៏មានព្រះភាគ (/ ករុណា / ករុណាទាំងឡាយ / សង្ឃ) អត់នូវទោសកំហុស

នោះដល់ខ្ញុំព្រះករុណា ព្រោះអំពើនៃទោសនោះជាសេចក្តីខុសពិត ដើម្បីនឹងបានសង្រួម គឺថានឹងប្រព្រឹត្ត អោយល្អតទៅក្នុងខាងមុខនោះហោង។

រួចបើជាបុគ្គល រឺគណៈ រឺសង្ឃដែលនៅជាប្រធាននៅទីនោះត្រូវទទួលថា សាធុ ប្រែថា ប្រពៃហើយ

បើបុរសត្រូវសូតថា យោហំ ថា តស្សមេ បើស្ត្រីត្រូវសូត្រថា យាហំ ថា តស្សា មេ តាមគួរដល់បាលី ដែលត្រូវផ្លាស់ តាមបុរសស្ត្រី ទោះបុរសក្តី ស្ត្រីក្តីបើសូមខមាទោសក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបផ្លាស់ រឺចំពោះនឹងព្រះសថូបព្រះចេតីយ ដែលបញ្ចុះព្រះសារីរិកធាតុព្រះសម្មាសម្ពុទ្ធនោះត្រូវសូត្រថា ភគវតា វា ថា ភន្តេ ភគវា ថាបដិគ្គណ្ហាតុ បើចំពោះភិក្ខុ១រូបត្រូវសូត្រថា ពុទ្ធស្ស វា ថា ភន្តេ អយ្យោ ថាបដិគ្គណ្ហាតុ បើ ចំពោះគណៈភិក្ខុ២រូប រឺ៣រូប ត្រូវសូត្រថា ពុទ្ធស្ស វា ថា ភន្តេ សង្ឃោ ថា បដិគ្គណ្ហាតុ ត្រង់សេចក្តីប្រែ ក៏ មានរបៀបតាមជួរបាលីដែលគាបនោះដែរ។

បើសុទ្ធតែបុរស រឺសុទ្ធតែស្ត្រីច្រើននាក់ រឺបុរសនិងស្ត្រីច្រើននាក់លាយគ្នា តាំងពីពីរនាក់ឡើងទៅ ហើយ សូត្រសូមខមាទោសព្រមគ្នានោះត្រូវសូត្រថា

អច្ចយោ នោ ភន្តេ អច្ចគមា យថាពា (លេ/លា) យថាមុ (ល្ហេ/ល្ហា) យថាកុស
(លេ/លា) (យេ/យា)មយំ ភន្តេ កាយេន វា វាចាយ វា មនសា វា (ភគវតោ/ពុទ្ធ
ស្ស)វា ធម្មស្សវា សង្ឃស្ស វា អគារវំអកវិម្ហា (តេសំ/តាសំ) នោ ភន្តេ (ភគវា/
អយ្យោ/អយ្យា/សង្ឃោ) អច្ចយំ អច្ចយតោ បដិគ្គណ្ហ(តុ/តុ/ន្តុ/តុ)អាយតឹ សំវរាយ

សេចក្តីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាតែត្រង់ពាក្យថា ខ្ញុំព្រះករុណា ជា ខ្ញុំព្រះករុណាទាំងឡាយដូច្នេះវិញ ក្រៅពីនេះដូចគ្នាទាំងអស់។

បើបុរសត្រូវសូត្រថា យថាពាលេ យាមុល្ហេ យថាអកុសលេ យេមយំ ថា តេសំ នោ បើស្ត្រីត្រូវថា យថា ពាលា យថាមុល្ហា យថាអកុសលា យា មយំ តាសំ នោ បើទុកជាគ្នាច្រើនមានបុរសមានស្ត្រីលាយគ្នា ហើយសូត្រសូមខមាទោសព្រមគ្នានោះ ក៏ត្រូវសូត្រខុសគ្នាត្រង់បទដែលគាបនោះដែរ វៀរលែងតែត្រង់បទ ដែលគាប ៣អន្លើ គឺត្រង់បទថា ភគវតោ វា ពុទ្ធស្សវា ភគវា អយ្យោ អយ្យា សង្ឃោ បដិគ្គណ្ហាតុ បដិគ្គណ្ហ

ន្តុ នេះត្រូវសូត្រដូចគ្នាទាំងបុរសទាំងស្ត្រី តែបើគ្នាច្រើន ហើយសូត្រខមាទោសព្រមទាំងអស់គ្នានោះ បើមិនបាច់សូត្រដោយពាក្យជាពហុវចនៈតាមបែបខាងក្រោយនេះ និងសូត្រដោយពាក្យអែកវចនៈតាមបែបមុននោះក៏បាន ព្រោះសូត្រសូមខមាទោសព្រមទាំងអស់គ្នា លុះបានសូមខមាទោសនឹងព្រះរតនត្រៃដូច្នេះហើយ គប្បីបញ្ចេញវចីភេទប្តេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹក ដើម្បីនឹងអោយឡើងនាមបញ្ញាត្តិជាអុបាសក រឺអុបាសិកាក្នុងព្រះពុទ្ធសាសនាទៅ អែប្តេជ្ញានោះ នឹងប្តេជ្ញាក្នុងទីចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បាន ចំពោះនឹងព្រះសថូប រឺព្រះចេតីយដែលបញ្ចុះព្រះសារិរិកធាតុព្រះដ៏មានបុណ្យក៏បាន ចំពោះមុខបុគ្គល រឺគណៈសង្ឃក៏បាន បើបុរសតែម្នាក់ ស្ត្រីតែម្នាក់ ហើយសូត្រ ប្តេជ្ញាខ្លួនចំពោះបុគ្គល រឺគណៈ រឺសង្ឃនោះត្រូវប្តេជ្ញាដោយពាក្យថា

អេសាហំ ភន្តេ សុចិបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ចអុបា (សកំ/ សិកំ) មំ (អយ្យោ/ អយ្យា/ សង្ឃោ) ធារេ(តុ/ ន្តុ /តុ) អជ្ជតគ្គេបាណុបេតំ សរណំ គតំ

ប្រែថា បពិតព្រះ (ករុណា/ ករុណាទាំងឡាយ/ សង្ឃ) ដ៏ចំរើន ខ្ញុំព្រះករុណាសូមដល់នូវព្រះដ៏មានព្រះភាគដែលទ្រង់បរិនិព្វានទៅអស់កាលយូរអង្វែងហើយនោះផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះករុណាទាំងឡាយ ជ្រាបនូវខ្ញុំព្រះករុណាថាជាអុបា(សក/ សិកា) បានដល់ហើយនូវព្រះរតនត្រៃជាទីពឹងទីរលឹកស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ។

រួចបុគ្គល រឺគណៈ រឺសង្ឃត្រូវទទួលថា សាធុ ប្រែថា ប្រពៃហើយ។

បើបុរសត្រូវថា អុបាសកំ បើស្ត្រីត្រូវថា អុបាសិកំ ត្រង់ពាក្យថា អយ្យោ ធារេតុ អយ្យា ធារេន្តុ សង្ឃោ ធារេតុ នេះមានសេចក្តីអធិប្បាយដូចក្នុងវិធីសូមខមាទោសខាងដើម។

បើគ្នាច្រើនតាំងពីពីរនាក់ឡើងទៅ ទោះសុទ្ធតែបុរសក្តី សុទ្ធតែស្ត្រីក្តី បុរសនិងស្ត្រីលាយគ្នាក្តីត្រូវសូត្រថា

អេ (តេ/ តា) មយំ ភន្តេ សុចិរបរនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ចភិក្ខុសង្ឃញ្ច អុបា(សកេ/ កិកាយោ) នោ (អយ្យោ/ អយ្យា ស

សង្ឃា) ធារេ(តុ/ ន្តុ/តុ) អជ្ជតគ្គេ បាណុបេ (តេ/តា) សរណំ គ(តេ/តា)។

សេចក្ដីប្រែដូចគ្នានឹងបែបមុន ប្លែកគ្នាត្រង់ពាក្យមុនថា ខ្ញុំព្រះករុណា នោះក្នុងទីនេះថា ខ្ញុំព្រះករុណាទាំងឡាយ ដូច្នេះវិញ ក្រៅអំពីនោះនៅដូចគ្នាទាំងអស់។ បើបុរសតែម្នាក់ រឺស្រីតែម្នាក់ ហើយសូត្រប្ដេជ្ញាខ្លួនចំពោះព្រះពុទ្ធរូប រឺព្រះសថូបព្រះចេតីយដែលបញ្ចុះព្រះសារីរិកធាតុព្រះដ៏មានបុណ្យនោះ ត្រូវពោលប្ដេជ្ញាដោយពាក្យថា

អេសាហំ ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច អុបា

(សកំ/ សិកំ) មំ ភគវា ធារេតុ អជ្ជតគ្គេបាណុបេតំ សរណំ គតំ។

ប្រែថា បពិតព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំព្រះករុណាសូមដល់ព្រះដ៏មានព្រះភាគផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក សូមព្រះដ៏មានព្រះភាគទ្រង់ជ្រាប នូវខ្ញុំព្រះករុណាថា ជា(អុបាសក/ អុបាសិកា) បានដល់ហើយនូវព្រះរតនត្រៃជាទីពឹងទីរលឹកស្មើ ដោយជីវិត តាំងអំពីថ្ងៃនេះជាដើមរៀងទៅ។

បើច្រើនគ្នាក៏សូត្រដូចខាងលើ ដូរត្រង់បាលី ភគវន្តំ ជា ភគវា ប៉ុណ្ណោះ បើគ្នាច្រើនហើយ និងសូត្រប្ដេជ្ញាខ្លួនព្រមគ្នាដោយពាក្យជាអេកវចនៈក៏បាន ព្រោះសូត្រព្រមទាំងអស់គ្នា។

បុរសស្ត្រីកាលបើបានពោលពាក្យប្ដេជ្ញាខ្លួនជាអ្នកដល់ព្រះត្រៃសរណគមន៍ ជាទីពឹង ទីរលឹកដូច្នេះហើយក៏បាននាមបញ្ញាត្តិថា អុបាសក អុបាសិកា ក្នុគណនោះអែង។

វិធីខមាទោសក្ដី វិធីប្ដេជ្ញាខ្លួនជាអុបាសក អុបាសិកាក្ដី បើអ្នកដែលមិនចេះសូត្រជា បាលី សូមសូត្រប្ដេជ្ញាជាសំរាយតាមភាសាររបស់ខ្លួនក៏បាន តែបើអាចសូត្រទាំងបាលី និងសំរាយ រិតតែជាការប្រសើណាស់ តែសូមកុំសូត្រតែបាលីសុទ្ធ មិនដឹងជាអ្វីនោះឡើយ ព្រោះកិច្ចដែលសូត្រខមាទោស នឹងប្ដេជ្ញាខ្លួននេះធ្វើចំពោះយកសទ្ធា គឺសេចក្ដីជឿជាក់ និងបញ្ញា ជាសម្មាទិដ្ឋិដែលដឹងពិត យល់ត្រូវពិត ជាប្រមាណ។

ចប់បុព្វភាគប្បដិបត្តិតែប៉ណ្ណោះ។